ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៥ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីបុណ្យទន្លេលើកទី៦ នៅខេត្តបាត់ដំបង ពីថ្ងៃទី១៣ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៤ ស្តីពីពិធីបុណ្យទន្លេ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីបុណ្យទន្លេលើកទី៦ នៅខេត្តបាត់ដំបង ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៣ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០ ក្រោមប្រធានបទ ទន្លេនៃសន្តិភាព ទន្លេនៃវិបុលភាព ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **ងួន រតនៈ** | អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | អនុប្រធានអចិន្ត្រៃយ៍ |

៣-ឯកឧត្តម **ទិត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
៤-ឯកឧត្តម **ជា ម៉ូរ៉ា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
៥-ឯកឧត្តម **អ៊ុក សុជាតិ** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អនុប្រធាន
៦-ឯកឧត្តម **ឈួន ដារ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន
៧-ឯកឧត្តម **ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
៨-ឯកឧត្តម **សាន់ សាច់អី** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
៩-ឯកឧត្តម **នូ សុវត្ថិ** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក
១០-ឯកឧត្តម **សំ សិរីរតន៍** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
១១-ឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១២-ឯកឧត្តម **ជា សំអាង** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
១៣-ឯកឧត្តម **ណែត នឿត** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ សមាជិក
១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **ទូច ណារ៉ុថ** អគ្គស្នងការរងនគរបាលជាតិ សមាជិក
១៥-ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ឹម យ៉ាន** អគ្គស្នងការរងនគរបាលជាតិ សមាជិក
១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឃុន សំបូរ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សមាជិក
១៧-លោកឧត្តមសេនីយ៍ឯក **ម៉ន សាម៉ុន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៨-លោក **យស សុខេមរៈ** ប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
១៩-លោក **យូ ហេង** ប្រធានសាខាគយនិងរដ្ឋាករខេត្តបាត់ដំបង សមាជិក។

**ប្រការ២ .-**

គណៈកម្មការអន្តរក្រសួងនេះមានតួនាទីនិងភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំពិធីបុណ្យទន្លេលើកទី៦ នៅខេត្តបាត់ដំបង ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៣ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០។

**ប្រការ៣ .-**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាសេនាធិការ និងអនុគណៈកម្មការអន្តរក្រសួងមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើថវិការបស់ក្រសួងទេសចរណ៍និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់និងឧបត្ថម្ភបន្ថែមដល់ដំណើរការរៀបចំពិធីបុណ្យទន្លេឆ្នាំ២០២០។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

អនុប្រធាននិងសមាជិកនៃគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអ្នកជំនាញពាក់ព័ន្ធផ្សេងៗទៀត ចូលរួមកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង។

**ប្រការ៦ ._**

គណៈកម្មការអន្តរក្រសួងនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មករា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ